# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១៨-៨-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៨០៦/៣៥៥ ស្តីពីការបង្កើតគណៈកម្មាធិការមួយឈ្មោះថា "គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ " ដែលមានឈ្មោះជាអក្សរកាត់ថា " គ.ជ.វ.វ " ៦០០៦

២១-៨-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៨០៦/៣៥៧ ស្តីពីការតែងតាំងលោក **លី ម៉ោយូ** ជាឧកញ៉ា ៦០១១

២១-៨-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៨០៦/៣៥៩ ស្តីពីការប្រោសព្រះរាជទាន ចំពោះឧកញ៉ា **សេង ថន** នូវ គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ៦០១២

២២-៨-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៨០៦/៣៦០ ស្តីពីការតែងតាំង ឯកឧត្តម **សួរ ចាន់ធី** ជាអគ្គាធិការ នៃអគ្គាធិការដ្ឋានកិច្ចការតុលាការ ក្រសួងយុត្តិធម៌ ៦០១៣

២៣-៨-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៨០៦/៣៦១ ស្តីពីការបញ្ឈប់មុខតំណែង សម្តេចឧត្តមចរិយា **ឈឹង ប៊ុនឈា** ពីសាកលវិទ្យាធិការពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ និងតែងតាំងសម្តេចព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត** ព្រះសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា ជា សាកលវិទ្យាធិការពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ ៦០១៤


## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


២២-៨-២០០៦ -អនុក្រឹត្យលេខ ៨៤ អនក្រ.បក ស្តីពីការបង្កើតអង្គភាពប្រឆាំងអំពើពុករលួយ ៦០១៥

២២-៨-២០០៦ -អនុក្រឹត្យលេខ ៨៥ អនក្រ.បក ស្តីពីការលុបអនុក្រឹត្យស្តីពីការបង្កើតខុទ្ទកាល័យសម្តេចព្រះសង្ឃរាជគណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យស្តីពីការតែងតាំងមន្ត្រីសង្ឃ ៦០២០

២៣-៨-២០០៦ -អនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៦០២១

២២-៨-២០០៦ -អនុក្រឹត្យលេខ ៥៦១ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៦០២៣

២៣-៨-២០០៦ -អនុក្រឹត្យលេខ ៥៦២ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៦០២៤

២៣-៨-២០០៦ -អនុក្រឹត្យលេខ ៥៦៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦០២៥

២៣-៨-២០០៦ -អនុក្រឹត្យលេខ ៥៦៤ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៦០២៦

២៣-៨-២០០៦ -អនុក្រឹត្យលេខ ៥៦៥ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៦០២៧

២៣-៨-២០០៦ -អនុក្រឹត្យលេខ ៥៦៦ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ៦០២៨

២៣-៨-២០០៦ -អនុក្រឹត្យលេខ ៥៦៧ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៦០៣៣

២៣-៨-២០០៦ -អនុក្រឹត្យលេខ ៥៦៨ អនក្រ.តត ស្ដីពីការជូនមេដាយសហមេត្រី ៦០៣៤

## ២-សេចក្ដីសំរេច

២១-៨-២០០៦ -សេចក្ដីសំរេចលេខ ៣៧ សសរ ស្ដីពីការកែសំរួលសេចក្ដីសំរេច ស្ដីពីការបង្កើតក្រុមការងារ
តាមវិស័យសំរាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយផ្នែកឯកជន ៦០៣៥

## III-ការងារបណ្ដាក្រសួង

### ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

៣០-៦-២០០៦ -លិខិតបញ្ជាក់លេខ ១៦៣៨ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល
ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ដួងធីសាយហ្គន-ខេមបូឌាន**
**( អេស ឌី ស៊ី )** ៦០៣៨

៣០-៦-២០០៦ -លិខិតបញ្ជាក់លេខ ១៦៣៩ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល
ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ដួងធីសាយហ្គន-មិញហ្វៀក**
**( អេស ម៊ី ខេ )** ៦០៤០

៣០-៦-២០០៦ -លិខិតបញ្ជាក់លេខ ១៦៤១ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល
ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វណ្ណា វីដា** ៦០៤២

៣០-៦-២០០៦ -លិខិតបញ្ជាក់លេខ ១៦៤២ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល
ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គ័ន នេង អ៊ីមផត អិចផត** ៦០៤៤

០៣-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៦៤៥ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល
ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **កុល វាសនា អ៊ិនវេសមេន**
**ខូ អិលធីឌី** ៦០៤៦

០៣-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៦៥៣ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល
ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សាន់ រ៉ូយ៉ាល់** ៦០៤៨

០៣-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៦៥៤ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល
ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អង្គរវត្ត មីនើរ៉ល** ៦០៥០

០៣-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៦៥៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិម អេស ប៊ី អាស្ត្រោ អ៊ិនធើណេសិនណល** ៦០៥២

០៣-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៦៥៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស៊ាន គ្រេស អេនធើប្រាយ** ៦០៥៤

០៣-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៦៥៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សុខ លីហួរ គ្រុប ខូ អិលធីឌី** ៦០៥៦

០៣-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៦៦០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ព្រោមឿ ខនសាល់ធីង (ខេមបូឌា)** ៦០៥៨

០៣-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៦៦១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហាយលែនឌើរ ដៅវ៉េរ ស៊ីស្ទឹម លីមីធីត** ៦០៦០

០៣-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៦៦២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស្រ៊ុន ហេង សេង លី អ៊ិមផត អិចផត ឌីវេឡុបមេន** ៦០៦២

០៣-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៦៦៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ៊ុយ គីម ត្រេឌីង** ៦០៦៤

០៣-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៦៦៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឡុង ស៊ីញ** ៦០៦៦

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៦/៣៥៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ ..**

ត្រូវបានបង្កើតគណៈកម្មាធិការមួយឈ្មោះថា “ គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ” ដែលមានឈ្មោះជាអក្សរកាត់ថា “គ.ជ.វ.វ”

និងមានឈ្មោះជាភាសាអង់គ្លេសថា " National Committee for the Management of Decentralization and Deconcentration Reform (NCDD) "។

## ជំពូកទី ២
## សមាសភាព និងបេសកកម្ម

**មាត្រា ២ .-**

គ.ជ.ប.ប នេះមានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ជាប្រធាន |
| ២- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ជាអនុប្រធាន |
| ៣- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាអនុប្រធាន |
| ៤- រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ | ជាសមាជិក |
| ៥- រដ្ឋមន្ត្រីក្រសួងផែនការ | ជាសមាជិក |
| ៦- រដ្ឋមន្ត្រីក្រសួងកិច្ចការនារី | ជាសមាជិក |
| ៧- រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | ជាសមាជិក |
| ៨- រដ្ឋលេខាធិការក្រសួងមហាផ្ទៃមួយរូប | ជាសមាជិកអចិន្ត្រៃយ៍ |

គ.ជ.ប.ប អាចអញ្ជើញរដ្ឋមន្ត្រីក្រសួងផ្សេងៗទៀតចូលរួមប្រជុំតាមការចាំបាច់។

សមាជិកម្នាក់ៗរបស់ គ.ជ.ប.ប អាចតែងតាំងតំណាងមួយរូបដែលជាសមាជិករាជរដ្ឋាភិបាល ដើម្បីជំនួសខ្លួននៅក្នុងការចូលរួមកិច្ចប្រជុំទាំងអស់ ឬកិច្ចប្រជុំណាមួយ ដោយផ្តល់អំណាចឱ្យតំណាងរូបនោះអាចមានសិទ្ធិសម្រេចជំនួសសមាជិកនោះ។

**មាត្រា ៣ .-**

គ.ជ.ប.ប មានបេសកកម្មសំខាន់ៗដូចខាងក្រោម ៖

- បន្តមុខងារ និងភារកិច្ចរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និងគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ ដោយមុខងារនិងភារកិច្ចទាំងនោះត្រូវប្រចាប់បញ្ចូលជាស្វ័យប្រវត្តិទៅក្នុងការទទួលខុសត្រូវ និងសមត្ថកិច្ចរបស់ គ.ជ.ប.ប។

- សិក្សាស្រាវជ្រាវ និងអនុវត្តនូវយុទ្ធសាស្ត្រ និងកម្មវិធីសម្រាប់ការធ្វើអន្តរកាល ការប្រចាប់បញ្ចូល និងការរំសាយកម្មវិធីសិលាជាបណ្តើរៗ បន្ទាប់ពីកម្មវិធីនេះត្រូវបញ្ចប់នៅដំណាច់ឆ្នាំ២០០៦។

- តាក់តែង និងអនុវត្តកម្មវិធីជាតិជាបឋមសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិតេយ្យនៅថ្នាក់ក្រោមជាតិ។

- រៀបចំ និងអនុម័តនូវក្របខ័ណ្ឌជាបឋមសម្រាប់អនុវត្តមួយដែលមានចែងពីសមាសភាគ កាលបរិច្ឆេទ និងសកម្មភាពបណ្តោះអាសន្ននានានៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងអំឡុងពេលរង់ចាំការប្រកាសឱ្យប្រើនូវច្បាប់អង្គការ។

- សិក្សាស្រាវជ្រាវ អភិវឌ្ឍន៍ និងផ្តល់អនុសាសន៍ដល់រាជរដ្ឋាភិបាល ក្នុងការបង្កើតនូវមូលនិធិសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដ៏សមស្របមួយ ដើម្បីប្រមូលផ្តុំប្រភពធនធានម្ចាស់ជំនួយនានា សម្រាប់តម្រូវការផ្នែកបុគ្គលិក និងកិច្ចសហប្រតិបត្តិការរបស់គណៈកម្មាធិការជាតិ ការផ្តល់មូលនិធិសម្រាប់ការអភិវឌ្ឍន៍ និងតម្រូវការចាំបាច់នានានៅថ្នាក់ក្រោមជាតិ ព្រមទាំងការផ្តល់ជំនួយបច្ចេកទេសដល់ក្រសួងពាក់ព័ន្ធនានា។

- ស្រាវជ្រាវ ពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍ដល់រាជរដ្ឋាភិបាលអំពីជម្រើសដ៏ល្អបំផុតនៃការកៀរគរមូលនិធិអន្តរជាតិសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

- ស្រាវជ្រាវ និងរៀបចំនូវកិច្ចព្រមព្រៀងមួយរវាងរាជរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយស្តីពីការគាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីធានាថាគ្រប់ម្ចាស់ជំនួយទាំងអស់ត្រូវតែជាភាគីនៃកិច្ចព្រមព្រៀងនេះ ដែលជាការធានានូវការតម្រឹមជំនួយ។

- ធានាឱ្យមានការសម្របសម្រួល និងការពិភាក្សាយ៉ាងគ្រប់គ្រាន់ក្នុងចំណោម គ.ជ.វ.វ ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ ក្នុងការផ្ទេរមុខងារ អំណាច និងធនធានពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ។

- បង្កើតនូវវេទិកាដ៏សមស្របមួយរវាងរាជរដ្ឋាភិបាល និងម្ចាស់ជំនួយសម្រាប់សម្របសម្រួលកិច្ចសហប្រតិបត្តិការ និងការកៀរគរជំនួយសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

**មាត្រា ៤ ..**

គ.ជ.វ.វ អាចស្នើឱ្យក្រសួង ឬស្ថាប័នជាតិណាមួយផ្តល់នូវព័ត៌មានពាក់ព័ន្ធនឹងការអនុវត្តន៍តាមកម្មវិធីជាតិជាបឋម ព្រមទាំងអាចស្នើឱ្យស្ថាប័ននោះអនុវត្តដោយអនុលោមតាមកាលបរិច្ឆេទដែលបានកំណត់យ៉ាងច្បាស់លាស់ដោយ គ.ជ.វ.វ។

**មាត្រា ៥ ..**

គ.ជ.វ.វ ចេញសេចក្តីសម្រេច និងសេចក្តីណែនាំនានាផ្អែកតាមសមត្ថកិច្ច និងការទទួលខុសត្រូវដែលបានកំណត់ក្នុងព្រះរាជក្រឹត្យនេះ។

**មាត្រា ៦ ..**

ផ្អែកតាមសមត្ថកិច្ចរបស់ខ្លួន គ.ជ.វ.វ អាចស្នើយោបល់ក្នុងការរៀបចំសេចក្តីព្រាងច្បាប់ព្រះរាជក្រឹត្យ ឬអនុក្រឹត្យស្របតាមនីតិវិធីជាធរមាន។

**មាត្រា ៧ ..**

គ.ជ.វ.វ ត្រូវប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ។

**មាត្រា ៨ ..**

គ.ជ.វ.វ នឹងបញ្ចប់អាណត្តិរបស់ខ្លួនក្នុងពេលដែលយន្តការមួយសម្រាប់ដឹកនាំការអនុវត្តន៍ច្បាប់អង្គការត្រូវបានបង្កើតឡើងដោយអនុលោមតាមច្បាប់អង្គការ។

## ជំពូកទី ៣
## រចនាសម្ព័ន្ធ របៀបរបបការងារ និងលេខាធិការដ្ឋាន

**មាត្រា ៩ ..**

គ.ជ.វ.វ មានសិទ្ធិបង្កើតអនុគណៈកម្មការនានាតាមការចាំបាច់ដើម្បីជាជំនួយការលើផ្នែកជំនាញនីមួយៗរបស់ខ្លួន។

**មាត្រា ១០ ..**

គ.ជ.វ.វ ត្រូវជួបប្រជុំសាមញ្ញរៀងរាល់ពីរខែម្តង។

គ.ជ.វ.វ អាចធ្វើការប្រជុំវិសាមញ្ញបានតាមការចាំបាច់ តាមការស្នើសុំរបស់ប្រធាន និងសមាជិកពីររូបនៃ គ.ជ.វ.វ។

គ.ជ.វ.វ ត្រូវរៀបចំ និងអនុម័តនូវនីតិវិធីការងាររបស់ខ្លួន។

**មាត្រា ១១ ..**

ត្រូវបានបង្កើតក្រុមការងារមួយសម្រាប់ជាជំនួយការឱ្យ គ.ជ.វ.វ ដែលនឹងកំណត់ដោយអនុក្រឹត្យ ។

ក្រុមការងារនេះអាចអញ្ជើញតំណាងក្រសួងផ្សេងៗទៀតឱ្យចូលរួមពិភាក្សា និងបំពេញការងារតាមការចាំបាច់។

ក្រុមការងារមានភារកិច្ចណែនាំ សម្របសម្រួលការងារចន្លោះពីការប្រជុំមួយទៅការប្រជុំមួយទៀតរបស់ គ.ជ.វ.វ ទៅតាមការសម្រេចរបស់ គ.ជ.វ.វ។

តួនាទី ភារកិច្ច និងរបៀបរបបធ្វើការងាររបស់ក្រុមការងារ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ គ.ជ.វ.វ។

**មាត្រា ១២ ..**

គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ត្រូវយកអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ ធ្វើជាលេខាធិការដ្ឋាន។

លេខាធិការដ្ឋានត្រូវបំពេញរាល់កិច្ចការចាំបាច់ ដើម្បីធានាការបំពេញមុខងាររបស់ គ.ជ.វ.វ និងក្រុមការងារឱ្យបានសមស្រប។

## ជំពូកទី ៤

## ប្រភពធនធានថវិកា

**មាត្រា ១៣ ..**

គ.ជ.វ.វ ត្រូវមានគម្រោងថវិកាដើម្បីបំពេញការងាររបស់ខ្លួនដែលសមស្របនឹងតម្រូវការនានានៃក្របខ័ណ្ឌជាបឋមសម្រាប់អនុវត្ត។

គ.ជ.វ.វ អាចទទួលជំនួយផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ និងសម្ភារៈពីប្រភពក្នុងប្រទេស និង ក្រៅប្រទេសសម្រាប់អនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ១៤ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៥ ..**

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងសមាសភាពដូចមានចែងក្នុងមាត្រា២ និង មាត្រា១១ ត្រូវអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០០៦

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកត/០៨០៦/៣៧៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ ៣៧៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ២០០៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ឌិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៦/៣៥៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា )

**តែងតាំង**

លោក **លី ឈៀយូ**

ជា

**ឧកញ៉ា**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រស.០៦០៨.៣៧៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៦

លេខ : ៣៤១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០០៦
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៦/៣៥៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមររាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា )

ប្រោសព្រះរាជទាន

ចំពោះ :

ឧកញ៉ា **សង ឋន**

នូវ

**គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រស.០៦០៥.៣៤០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៦

លេខ : ៣៣៧ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០០៦
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៦/៣២០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា អគ្គមហាក្សត្រ ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងឯកឧត្តម **សួរ ចាន់ធី** ជាអគ្គាធិការ នៃអគ្គាធិការដ្ឋានកិច្ចការតុលាការ ក្រសួងយុត្តិធម៌ ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ៕

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ:៣៣៧ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ,ថ្ងៃទី២៣ ខែ[illegible] ឆ្នាំ២០០៦
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

តរល.០២០៨.៣៩១

*ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៦*

**ឃុន ជិនកេន**

នស/រកត/០៨០៦/៣៦១

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៤០៦/១៩២ ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការតែងតាំងគណៈគ្រប់គ្រងពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** បញ្ឈប់ពីមុខតំណែង សម្តេចព្រះឧត្តមចរិយា ឈឹង ប៊ុនឈា ពីសាកលវិទ្យាធិការពុទ្ធិកសាកលវិទ្យាល័យ ព្រះសីហនុរាជ ។

**មាត្រា ២ :** តែងតាំង សម្តេចព្រះមហាសុមេធាធិបតី នន្ទ ង៉ែត ព្រះសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា ជាសាកលវិទ្យាធិការពុទ្ធិកសាកលវិទ្យាល័យ ព្រះសីហនុរាជ។

**មាត្រា ៣ :** រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៥ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ : ៣៤៣ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ៧ ឆ្នាំ២០០៦
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

ពរល.០៦០៨.៣៥៧

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៦*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៧៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតអង្គភាពប្រឆាំងអំពើពុករលួយ

~~~~~~~~

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា១.-**

ត្រូវបានបង្កើតអង្គភាពប្រឆាំងអំពើពុករលួយ ហៅកាត់ថា " អ.ប.អ.ព " ដែលស្ថិតនៅក្រោមឱវាទទីស្តីការគណៈរដ្ឋមន្ត្រី។
~~~~~~~~

**មាត្រា២ ._**

អង្គភាពប្រឆាំងអំពើពុករលួយ មានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម **ឱម យ៉ិនទៀង** | ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី | ប្រធាន |
| ២-ឯកឧត្តម **មល់ រឿប** | ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៣-ឯកឧត្តម **ព្រំ សុខា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤-ឯកឧត្តម **ធីយ រឿន** | អគ្គលេខាធិការរងរាជរដ្ឋាភិបាល | អនុប្រធាន |
| ៥-ឯកឧត្តម **ឆេង សារឿន** | រដ្ឋលេខាធិការក្រសួងទំនាក់ទំនងជាមួយព្រឹទ្ធសភា រដ្ឋសភា និងអធិការកិច្ច | សមាជិក |
| ៦-ឯកឧត្តម **ហង់ជួន ណារ៉ុន** | អគ្គលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧-ឯកឧត្តមឧត្តមសេនីយ៍ឯក **នេត សាវឿន** | អគ្គស្នងការរងនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ | សមាជិក |
| ៨-ឯកឧត្តមឧត្តមសេនីយ៍ឯក **ជុំ ហាក់** | មេបញ្ជាការរងកងទ័ពជើងគោក | សមាជិក |
| ៩-ឯកឧត្តម **ម៉ុន ហុន** | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ១០-ឯកឧត្តមឧត្តមសេនីយ៍ទោ **ខន្ធ ពិសេន** | មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១១-លោក **សរ សម្បត្តិ** | ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិកប្រចាំការ |

**មាត្រា៣ ._**

អង្គភាពប្រឆាំងអំពើពុករលួយ មានបេសកកម្មក្នុងការធ្វើសកម្មភាព ដោយផ្តោតសំខាន់លើកត្តាជាសារវ័ន្ត៣ ដែលមានភាពប្រទាក់ក្រឡាគ្នា គឺ ការបង្ការទប់ស្កាត់ជាមុន ការពង្រឹងការអនុវត្តច្បាប់ និងការគាំទ្រពីមហាជន ក្នុងការប្រយុទ្ធប្រឆាំងកំចាត់អំពើពុករលួយ ។

អង្គភាពប្រឆាំងអំពើពុករលួយមានតួនាទី និងភារកិច្ច ដូចតទៅ :

-ប្រមែប្រមូលគ្រប់ឯកសារ និងព័ត៌មានពាក់ព័ន្ធអំពើពុករលួយគ្រប់ប្រភេទ និងរក្សាការសម្ងាត់នៃប្រភពទទួលព័ត៌មាន ស្តីពីការកើតមានអំពើពុករលួយ

-ពិនិត្យ និងរៀបចំឯកសារ ព្រមទាំងលើកឡើងគំនិតផ្តួចផ្តើមពាក់ព័ន្ធនឹងការប្រឆាំងកំចាត់អំពើពុករលួយ ដែលមានចរិតជាចក្ខុវិស័យ ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល

-រៀបចំកសាងផែនការសកម្មភាពប្រឆាំងអំពើពុករលួយ

-ទទួល និងពិនិត្យរាល់ពាក្យបណ្តឹងដែលពាក់ព័ន្ធនឹងអំពើពុករលួយ

-តាមដាន ស៊ើបអង្កេត ត្រួតពិនិត្យ និងធ្វើការសិក្សាស្រាវជ្រាវ ព្រមទាំងលើកឡើងនូវវិធានការនានាពាក់ព័ន្ធនឹងបទល្មើសពុករលួយនៅតាមក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ ក្រុមហ៊ុនរដ្ឋ និងអាជ្ញាធរដែនដីខេត្ត ក្រុង ព្រមទាំងចាត់ការទៅតាមនីតិវិធីជាធរមាន

-អនុវត្តនូវវិធានការរបស់រាជរដ្ឋាភិបាល តាមរយៈការអប់រំ ឃោសនា ផ្សព្វផ្សាយ ការបង្ការ ការទប់ស្កាត់ ការជំរុញការអនុវត្តច្បាប់ និងការបង្ក្រាបអំពើពុករលួយ

-ធ្វើទំនាក់ទំនង សម្របសម្រួល និងកៀរគរធនធាន និងជំនួយអន្តរជាតិ

-ធ្វើរបាយការណ៍ ស្តីពីសកម្មភាពការងាររបស់ខ្លួនតាមកាលកំណត់ជូនប្រមុខរាជរដ្ឋាភិបាល ។

**មាត្រា៤ .-**

អង្គភាពប្រឆាំងអំពើពុករលួយ មានរចនាសម្ព័ន្ធដូចតទៅ :

១-ផ្នែករដ្ឋបាល ហិរញ្ញកិច្ច និងធនធានមនុស្ស

២-ផ្នែកអប់រំ បង្ការ ទប់ស្កាត់ និងសហប្រតិបត្តិការ

៣-ផ្នែកស៊ើបអង្កេត

៤-ផ្នែកជំរុញការអនុវត្តច្បាប់ ។

ផ្នែកនីមួយៗត្រូវដឹកនាំ និងគ្រប់គ្រងដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ ។

**មាត្រា៥ .-**

ផ្នែករដ្ឋបាល ហិរញ្ញកិច្ច និងធនធានមនុស្ស មានតួនាទី និងភារកិច្ចដូចតទៅ :

-ទទួល និងពិនិត្យរាល់លិខិតចូលពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងពាក្យបណ្តឹងនានា ព្រមទាំងបញ្ជូនលិខិតឯកសារទៅផ្នែកថ្នាក់ដឹកនាំ និងក្រសួង ស្ថាប័នពាក់ព័ន្ធ

-លើក និងអនុវត្តគម្រោងថវិកាប្រចាំឆ្នាំ ព្រមទាំងគ្រប់គ្រងគណនេយ្យ និងហិរញ្ញកិច្ចរបស់អង្គភាពប្រឆាំងអំពើពុករលួយ

-គ្រប់គ្រង និងរៀបចំបណ្តុះបណ្តាលធនធានមនុស្ស ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីលើកកំពស់សមត្ថភាពជំនាញដល់មន្ត្រីរាជការក្នុងអង្គភាព និងក្រសួង ស្ថាប័នពាក់ព័ន្ធ

-ធ្វើសេចក្តីព្រាងបូកសរុបរបាយការណ៍ ស្តីពីសកម្មភាពការងាររបស់អង្គភាព តាមកាលកំណត់ ជូនប្រធានអង្គភាព ពិនិត្យ និងសម្រេច

-អនុវត្តភារកិច្ចផ្សេងៗទៀត តាមការណែនាំរបស់ប្រធានអង្គភាព ។

**មាត្រា៦ .-**

ផ្នែកអប់រំ បង្ការ ទប់ស្កាត់ និងសហប្រតិបត្តិការ មានតួនាទី និងភារកិច្ចដូចតទៅ :

-កសាងផែនការសកម្មភាព ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើពុករលួយតាមទស្សនៈ កម្មវិធីនយោបាយយុទ្ធសាស្ត្រចតុកោណ និងផែនការអភិវឌ្ឍន៍ជាតិ

-កសាងឯកសារយុទ្ធសាស្ត្រប្រឆាំងនឹងអំពើពុករលួយក្នុងអភិបាលកិច្ចល្អ

-ធ្វើសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំកិច្ចប្រជុំ សិក្ខាសាលាថ្នាក់ជាតិ អន្តរជាតិ និងបង្កើតកម្មវិធីផ្សេងៗ ដើម្បីផ្សព្វផ្សាយដល់មហាជនឱ្យយល់ដឹងអំពីផលវិបាកនៃអំពើពុករលួយ

-ធ្វើការអប់រំក្រមសីលធម៌វិជ្ជាជីវៈដល់មន្ត្រីរាជការ អាជ្ញាធរដែនដី សិស្សានុសិស្ស និស្សិត កងកម្លាំងប្រដាប់អាវុធ និងមហាជន ដើម្បីចូលរួមក្នុងការបង្ការទប់ស្កាត់ និងកំចាត់អំពើពុករលួយ

-ជំរុញ និងលើកទឹកចិត្តដល់គ្រប់មជ្ឈដ្ឋានសាធារណៈទាំងអស់ ឱ្យចូលរួមផ្តល់ព័ត៌មានពាក់ព័ន្ធនឹងអំពើពុករលួយ

-ធ្វើសហប្រតិបត្តិការជាមួយស្ថាប័នជាតិ និងអន្តរជាតិ ក្នុងគោលដៅប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ និងស្វែងរកជំនួយឧបត្ថម្ភពីដៃគូនានា ទាំងសម្ភារៈ បច្ចេកទេសជំនាញ និងថវិកា

-ធ្វើរបាយការណ៍ ស្តីពីសកម្មភាពការងាររបស់ខ្លួនតាមកាលកំណត់ ជូនប្រធានអង្គភាព

-អនុវត្តភារកិច្ចផ្សេងៗទៀត តាមការណែនាំរបស់ប្រធានអង្គភាព ។

**មាត្រា៧ ..**

ផ្នែកស៊ើបអង្កេត មានតួនាទី និងភារកិច្ចដូចតទៅ :

-ទទួលពាក្យបណ្តឹង និងស្វែងរកព័ត៌មាន ដែលពាក់ព័ន្ធនឹងអំពើពុករលួយ

-សិក្សាស្រាវជ្រាវ និងប្រមូលឯកសារពាក់ព័ន្ធនឹងអំពើពុករលួយ រួចធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំអង្គភាព

-សហការជាមួយសមត្ថកិច្ច និងអាជ្ញាធរពាក់ព័ន្ធ ដើម្បីធ្វើការស៊ើបអង្កេតដល់ទីកន្លែងនូវរាល់ករណីពាក់ព័ន្ធនឹងការក្លែងបន្លំ ការកិបកេងទ្រព្យសម្បត្តិរដ្ឋ ការបាត់បង់ថវិកាជាតិ និងសកម្មភាពនៃអំពើពុករលួយផ្សេងទៀត

-តាមដានលើឯកសារ និងសកម្មភាពនៃការងារចំណូល ចំណាយថវិកាជាតិ និងការប្រើប្រាស់ជំនួយជាតិ និងអន្តរជាតិ ទៅតាមក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន អាជ្ញាធរដែនដីខេត្ត ក្រុង គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ និងក្រុមហ៊ុនរដ្ឋ ដើម្បីធ្វើការវាយតម្លៃ សន្និដ្ឋាន និងលើកវិធានការជូនថ្នាក់ដឹកនាំអង្គភាព

-ធ្វើរបាយការណ៍ ស្តីពីសកម្មភាពការងាររបស់ខ្លួនតាមកាលកំណត់ ជូនប្រធានអង្គភាព

-អនុវត្តភារកិច្ចផ្សេងៗទៀត តាមការណែនាំរបស់ប្រធានអង្គភាព ។

**មាត្រា៨ ..**

ផ្នែកជំរុញការអនុវត្តច្បាប់ មានតួនាទី និងភារកិច្ចដូចតទៅ :

-សិក្សា និងវិភាគពាក្យបណ្តឹងពាក់ព័ន្ធនឹងអំពើពុករលួយ ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីកំណត់បទល្មើស រួចស្នើសុំការសម្រេចពីថ្នាក់ដឹកនាំអង្គភាព

-សហការជាមួយផ្នែកស៊ើបអង្កេត និងផ្នែកពាក់ព័ន្ធ ព្រមទាំងនគរបាលយុត្តិធម៌ ក្នុងការរៀបចំបែបបទបញ្ជូនសំណុំរឿង និងជនល្មើសទៅតុលាការតាមនីតិវិធីជាធរមាន

-សិក្សាស្រាវជ្រាវឯកសារច្បាប់ និងលិខិតបទដ្ឋាននានា ទាំងក្នុង និងក្រៅប្រទេសដែលពាក់ព័ន្ធនឹងការប្រឆាំងនឹងអំពើពុករលួយ

-តាមដាន និងត្រួតពិនិត្យការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាល និងរបស់ក្រសួង ស្ថាប័ន ដើម្បីធានាបាននូវភាពសុចរិត ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព

-ធ្វើរបាយការណ៍ ស្តីពីសកម្មភាពការងាររបស់ខ្លួនតាមកាលកំណត់ ជូនប្រធានអង្គភាព

-អនុវត្តភារកិច្ចផ្សេងៗទៀត តាមការណែនាំរបស់ប្រធានអង្គភាព ។

**មាត្រា៩ .-**

អង្គភាពប្រឆាំងអំពើពុករលួយ មានខ្ទង់ថវិកាដោយឡែកមួយ នៅក្នុងថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

ធនធាន និងថវិការបស់អង្គភាពប្រឆាំងអំពើពុករលួយ ត្រូវផ្គត់ផ្គង់ដោយ :

-ថវិកាជាតិ

-ហិរញ្ញប្បទានពីអង្គការជាតិ និងអន្តរជាតិ ។

**មាត្រា១០ .-**

អង្គភាពប្រឆាំងអំពើពុករលួយ មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា១១ .-**

អនុក្រឹត្យលេខ ៩៦ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតអង្គភាពប្រឆាំងរាល់សកម្មភាពអំពើពុករលួយ និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា១២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ អភិបាលខេត្ត ក្រុង និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ២ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ សីហា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី

-ដូចមាត្រា១២

-រាជកិច្ច

-ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ..៨៥..អនក្រ.បក

## អនុក្រឹត្យ

## ស្ដីពី

## ការលុបអនុក្រឹត្យស្ដីពីការបង្កើតខុទ្ទកាល័យសម្ដេចព្រះសង្ឃរាជ គណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យស្ដីពីការតែងតាំងមន្ត្រីសង្ឃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាស អោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការបង្កើតខុទ្ទកាល័យ សម្ដេចព្រះសង្ឃរាជគណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៣៧៣ អនក្រ.បក ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងមន្ត្រីសង្ឃ
- យោងតាមសំណើរបស់ សម្ដេចព្រះអគ្គមហាសង្ឃរាជាធិបតី នៃព្រះរាជាណាចក្រកម្ពុជា

## សំរេច

**មាត្រា ១:-**

ត្រូវបានលុបអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការបង្កើតខុទ្ទកាល័យ សម្ដេចព្រះសង្ឃរាជគណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា និង អនុក្រឹត្យលេខ ៣៧៣ អនក្រ.បក ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងមន្ត្រីសង្ឃ ។

**មាត្រា ២:-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ[illegible] ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ...៨៦... អនក្រ.បក

## អនុក្រឹត្យ

## ស្ដីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ , ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្ដីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្ដីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៥/០៤០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្ដីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩៥ អនក្រ.បក , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្ដីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៨៦៤ លានរៀល (ប្រាំបីរយហុកសិបបួនលានរៀលគត់) ពីជំពូក ៤១ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៣០ (អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច) ជូនក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ចំណាយរៀបចំ និង ចូលរួមតាំងពិពរណ៍នៅខេត្តឈៀងម៉ៃ ប្រទេសថៃឡង់ដ៍ ២០០៦-២០០៧ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៣ ខែ ៧ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ ៗ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ៥០៦ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពី
## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ បក ចុះថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រង ការអនុវត្តការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**មាត្រា១.-** ត្រូវបានប្រគល់ភារកិច្ចជូនលោក **ម៉ា សុទណ្ណា** អោយបំពេញមុខងារជាប្រធាននាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ នៃក្រសួងអភិវឌ្ឍន៍ជនបទ ។

**មាត្រា២.-** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនិងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃ ចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែសីហា ឆ្នាំ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ៥៧២ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**សម្រេច**

**មាត្រា១:** ត្រូវបានបំពាក់ មេដាយសហមេត្រី ថ្នាក់ អស្សឫទ្ធិ ជូនអង្គការ NPA (ន័រវេស្ស ) ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការចុះបញ្ជីដីធ្លី និងផ្ទេរប័ណ្ណសំគាល់សិទ្ធិម្ចាស់អចលនវត្ថុ ជូនប្រជាពលរដ្ឋក្រីក្រ នៅភូមិប្រជាធម្ម ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ចំណាយអស់ ថវិកា ចំនួន ២០.០០០ ដុល្លារ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ០៨ ឆ្នាំ ២០០៦
នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៩៦៣...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក *Kodama TERUAKI* និងលោកស្រី *Kodama Hideko* ដែលបានផ្តល់ថវិកាតាមរយៈអង្គការ *JHP* មានទឹកប្រាក់ចំនួន ៣៣.៤៥០ ដុល្លារ សំរាប់ជួយសាងសង់អគារសិក្សា ០១ខ្នង និង បង្គន់អនាម័យ ០១ខ្នង នៅសាលាបឋមសិក្សាសេរីសោភ័ណ្ឌ ភូមិត្រពាំងពើក ឃុំកាត់ភ្លុក ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ ៧ ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ:...៥៦៤...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន១១រូប ដែលបានបរិច្ចាគថវិកា ជួយកសាងសមិទ្ធផលច្រើនប្រភេទ នៅវត្តទួលថ្មតម្រា ឃុំសំពៅពូន ស្រុកកោះធំ និងសាលាបឋមសិក្សាបារគូ ឃុំបារគូ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដូចមានរាយព្រះនាម និងនាមខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-ព្រះតេជគុណ | **ឆាន ឧទ្ធី** | ចៅអធិការវត្តទួលព្រះរាជា | បច្ច័យចំនួន | ១៩.៣៨៦ ដុល្លារ |
| ២-ព្រះតេជគុណ | **សុខ បញ្ញា** | ចៅអធិការវត្តទួលថ្មតម្រា | បច្ច័យចំនួន | ៣៨.០៤២ ដុល្លារ |
| ៣-លោកស្រី | **គង់ ពេជ្រ** | សប្បុរសជននៅប្រទេសអូស្ត្រាលី | ថវិកា ចំនួន | ៥៦.២១០ ដុល្លារ |
| ៤-លោក | **ស្រី ពៅ** | សប្បុរសជននៅប្រទេសអូស្ត្រាលី | ថវិកា ចំនួន | ៤៦.២៧០ ដុល្លារ |
| ៥-លោកស្រី | **គង់ ស្រី** | សប្បុរសជននៅប្រទេសអូស្ត្រាលី | ថវិកា ចំនួន | ៣៥.៥០០ ដុល្លារ |
| ៦-លោកស្រី | **ជ័យ លាភី** | សប្បុរសជននៅប្រទេសអូស្ត្រាលី | ថវិកា ចំនួន | ៣៥.១៣០ ដុល្លារ |
| ៧-កញ្ញា | **គង់ លីដា** | សប្បុរសជននៅប្រទេសអូស្ត្រាលី | ថវិកា ចំនួន | ១៩.០៥០ ដុល្លារ |
| ៨-លោកស្រី | ELYSABETH UPDIKA | សប្បុរសជននៅសហរដ្ឋអាមេរិក | ថវិកា ចំនួន | ១០.៥០០ ដុល្លារ |
| ៩-លោក | SAMBONN LEK | សប្បុរសជននៅសហរដ្ឋអាមេរិក | ថវិកា ចំនួន | ១០.៣០០ ដុល្លារ |
| ១០-លោក | BOPHA LEK | សប្បុរសជននៅសហរដ្ឋអាមេរិក | ថវិកា ចំនួន | ១០.២០០ ដុល្លារ |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| -លោក | **អ៊ិន អ៊ាង** | គណៈកម្មការវត្តទួលថ្មតម្រា | ថវិកា ចំនួន | ៥.៥៥០ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ [illegible] ឆ្នាំ ២០០៦

**ហ៊ុន សែន**

**កន្លែងទទួល :**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤១៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

៣៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ជូនលោក **ហែម សារិន** នាយកវងវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស នៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច បំរើជាតិមាតុភូមិ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ៨ ឆ្នាំ២០០៦

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៦៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

៚

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ក្រោមឱវាទ ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន១៤៦ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច បំរើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :-

**ក.មេដាយមាសការងារ :**

១-ឯកឧត្តម **ចាប ឫទ្ធី** អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ
២-ឯកឧត្តម **ឡេង ចំរើនដារ៉ា** អគ្គាធិការ នៃអគ្គាធិការដ្ឋាន
៣-លោក **កែវ សម្បត្តិ** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ
៤-លោក **ស៊ិន ម៉ៃឡៃ** អគ្គនាយករង នៃអគ្គនាយកដ្ឋាន TVET
៥-លោក **ឡឹក វណ្ណជន** អគ្គាធិការរង នៃអគ្គាធិការដ្ឋាន
៦-លោក **ហេង សួរ** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
៧-លោក **គីម អឿន** អគ្គនាយករង នៃអគ្គនាយកដ្ឋាន TVET
៨-លោក **ឌី សេរីវឌ្ឍ** អគ្គនាយករង នៃអគ្គនាយកដ្ឋានការងារ
៩-លោក **សុខ បូរី** អគ្គនាយករង នៃអគ្គនាយកដ្ឋានការងារ
១០-លោក **ខេត ណារិទ្ធ** អគ្គនាយករង នៃអគ្គនាយកដ្ឋាន TVET
១១-លោកស្រី **ស៊ើង សរសុចិន្តា** ប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងនីតិកម្ម

| | | |
|---|---|---|
| ១២-លោក | ហាច ហ៊ាន | ប្រធាននាយកដ្ឋានរដ្ឋបាល និង បុគ្គលិក |
| ១៣-លោក | ទី ស៊ីម៉ាណែត | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| ១៤-លោក | ឡេង តុង | ប្រធាននាយកដ្ឋានពេទ្យការងារ |
| ១៥-លោក | ទើង ហៀង | ប្រធាននាយកដ្ឋានការងារកុមារ |
| ១៦-លោក | ឃឹន ចន្ថា | ប្រធាននាយកដ្ឋានគ្រប់គ្រងកិច្ចការ TVET |
| ១៧-លោក | ផន់ ណារ៉ា | នាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលអភិវឌ្ឍន៍សហគ្រិនឥណ្ឌា |
| ១៨-លោក | ឃឹម សំអុល | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ |
| ១៩-លោក | ផង់ ថាវ៉េត | អនុប្រធាននាយកដ្ឋានស្តង់ដាជាតិ សមត្ថភាព |
| ២០-លោក | អាន ថៃសុជាតិ | អនុប្រធាននាយកដ្ឋានស្តង់ដាជាតិ សមត្ថភាព |
| ២១-លោក | អៀម គន្ធឌី | អនុប្រធាននាយកដ្ឋានស្តង់ដាជាតិ សមត្ថភាព |
| ២២-លោក | យូ សូគង | អនុប្រធាននាយកដ្ឋានព័ត៌មានទីផ្សារការងារ |
| ២៣-លោក | ខៀវ សាវុធ | អនុប្រធាននាយកដ្ឋានវិវាទការងារ |
| ២៤-លោក | លីន សំភាស | នាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈព្រែកព្នៅ |
| ២៥-លោក | ហូ ហួយ | នាយកមជ្ឈមណ្ឌលអភិវឌ្ឍន៍មុខជំនាញកម្ពុជា-ថៃ ពូនភ្នំ |
| ២៦-លោក | រស់ ប៉ិត | នាយករងមជ្ឈមណ្ឌលអភិវឌ្ឍន៍មុខជំនាញកម្ពុជា-ថៃ ពូនភ្នំ |
| ២៧-លោក | ពៅ ស៊ីថា | ប្រធានមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ឆ្នាំង |
| ២៨-លោក | ដួង សារ៉ាន់ | អនុប្រធានមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពត |
| ២៩-លោកស្រី | រស់ គន | អនុប្រធានមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រៃវែង |

**ខ. មេដាយប្រាក់ការងារ :**

| | | |
|---|---|---|
| ១-លោក | លាង វិសាល | អនុប្រធាននាយកដ្ឋានរដ្ឋបាល និង បុគ្គលិក |
| ២-លោក | សាលី មុនី | អនុប្រធាននាយកដ្ឋានរដ្ឋបាល និង បុគ្គលិក |
| ៣-លោក | គីម ធីមិត្ត | អនុប្រធាននាយកដ្ឋាន ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ |
| ៤-លោក | ហ៊ុង ស៊ីដេត | អនុប្រធាននាយកដ្ឋាន គ្រប់គ្រងកិច្ចការ TVET |
| ៥-លោក | ឡាយ ម៉េងលី | អនុប្រធាននាយកដ្ឋាន ពេទ្យការងារ |
| ៦-លោក | ជីវ គីមសាយ | ប្រធានគណៈកម្មការសាលាមធ្យមសិក្សាបច្ចេកទេសឧស្សាហកម្ម |
| ៧-លោក | យស សារ៉េត | នាយករងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈព្រែកព្នៅ |
| ៨-លោក | ស៊ុំ សោភ័ណ | អនុប្រធាននាយកដ្ឋាន សន្តិសុខសង្គម |
| ៩-លោក | អ៊ុង រ័ត្នធីណា | ប្រធានការិយាល័យ នាយកដ្ឋានមុខរបរ និង ហត្ថពលកម្ម |
| ១០-លោក | នេន វុឌ្ឍី | ប្រធានការិយាល័យ នាយកដ្ឋានព័ត៌មានទីផ្សារការងារ |
| ១១-លោក | កែវ ប៊ុនណា | អនុប្រធានការិយាល័យ នាយកដ្ឋាន សន្តិសុខសង្គម |
| ១២-លោក | ឈុំ វណ្ណារ៉េត | ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុងព្រះសីហនុ |
| ១៣-លោក | សន ប៊ុនធឿន | ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តរតនគិរី |
| ១៤-លោក | ឌិត ឡាយហ៊ាក | ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុងកែប |
| ១៥-លោក | អៀម សារិន | ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តក្រចេះ |
| ១៦-លោក | យ៉ាន ម៉េងគិច | អនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ធំ |
| ១៧-លោក | លី សុធា | អនុប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងនីតិកម្ម |
| ១៨-លោក | គាំ វីប៊ិន | អនុប្រធាននាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ |

១៩-លោក គង់ ចំនួនតារា អនុប្រធាននាយកដ្ឋាន ព័ត៌មានទីផ្សារការងារ
២០-លោក ខេង ខេមរា អនុប្រធាននាយកដ្ឋាន គ្រប់គ្រងកិច្ចការ TVET
២១-លោកស្រី នង កណ្ណិកា អនុប្រធាននាយកដ្ឋាន គ្រប់គ្រងកិច្ចការ TVET
២២-កញ្ញា ឌុង សុភាព អនុប្រធាននាយកដ្ឋាន ការងារកុមារ
២៣-លោក ជួប ណារ៉ាត់ អនុប្រធាននាយកដ្ឋាន មុខរបរ និង ហត្ថពលកម្ម
២៤-លោក ផេង ពុទ្ធរិទ្ធ អនុប្រធាននាយកដ្ឋាន អធិការកិច្ចការងារ
២៥-លោកស្រី ម៉ៅ ធីតា អនុប្រធាននាយកដ្ឋាន សវនកម្មផ្ទៃក្នុង
២៦-លោក សៅ អិ នាយករងវិទ្យាស្ថានពហុបច្ចេកទេស ព្រះកុសុមៈ
២៧-លោក អ៊ុក ដារ៉ា អនុប្រធានគណៈកម្មការសាលាមធ្យមសិក្សាបច្ចេកទេសឧស្សាហកម្ម
២៨-លោក ហាស់ ម៉ុនធី ប្រធានមន្ទីរ ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តស្វាយរៀង
២៩-លោក ឡុង សុធី ប្រធានមន្ទីរ ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តមណ្ឌលគិរី
៣០-លោក នុង វណ្ណី ប្រធានមន្ទីរ ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពត
៣១-លោក ហែម ហឿន ប្រធានមន្ទីរ ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តព្រៃវែង
៣២-លោក ហេង ភួយ ប្រធានមន្ទីរ ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប
៣៣-លោក សំ សំបូរ ប្រធានមន្ទីរ ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តឧត្តរមានជ័យ
៣៤-លោក ឌុល នាង ប្រធានមន្ទីរ ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល
៣៥-លោក ណាំ ឆេងអោង ប្រធានមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តបន្ទាយមានជ័យ

**គ-មេដាយសេវាការងារ :**

១-លោក តាង សាន ប្រធានការិយាល័យ នាយកដ្ឋានស្តង់ដាជាតិសមត្ថភាព
២-លោក សៅ សារិទ្ធ ប្រធានការិយាល័យ នាយកដ្ឋានស្តង់ដាជាតិសមត្ថភាព
៣-លោក ម៉ុន ហ៊ន ប្រធានការិយាល័យ នាយកដ្ឋានគ្រប់គ្រងកិច្ចការ TVET
៤-លោក អ៊ួន ស៊ីនថាត ប្រធានការិយាល័យ វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស
៥-លោក ឡេង ឆឿន ប្រធានការិយាល័យ សាលាមធ្យមសិក្សាបច្ចេកទេសឧស្សាហកម្ម
៦-លោក ម៉ិត ចាន់ ប្រធានការិយាល័យ សាលាមធ្យមសិក្សាបច្ចេកទេសឧស្សាហកម្ម
៧-លោក ឌួង គីមឈាង ប្រធានការិយាល័យ នាយកដ្ឋានពេទ្យការងារ
៨-លោក គឹម វណ្ណី អនុប្រធានការិយាល័យ វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ
៩-លោក ស៊ុម សំអាត អនុប្រធានការិយាល័យ វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ
១០-លោក យ៉ោក សុទ្ធី អនុប្រធានការិយាល័យ វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស
១១-លោក ឌា អ៊ុចហួត អនុប្រធានការិយាល័យ វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ
១២-លោកស្រី ស៊ិន សុភាព អនុប្រធានការិយាល័យ វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ
១៣-លោក លី គីមអ៊ាន អនុប្រធានការិយាល័យ វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស
១៤-លោក វណ្ណា វណ្ណៈ អនុប្រធានការិយាល័យ នាយកដ្ឋានមុខរបរ និង ហត្ថពលកម្ម
១៥-លោកស្រី ម៉ក់ សុវណ្ណា អនុប្រធានការិយាល័យ នាយកដ្ឋានមុខរបរ និង ហត្ថពលកម្ម
១៦-កញ្ញា ហុង មុំយ អនុប្រធានការិយាល័យ នាយកដ្ឋានមុខរបរ និង ហត្ថពលកម្ម
១៧-លោក ហួន សឿ អនុប្រធានការិយាល័យ នាយកដ្ឋានវិវាទការងារ
១៨-លោក ឆេស មុនី អនុប្រធានការិយាល័យ នាយកដ្ឋានអធិការកិច្ចការងារ
១៩-លោក យឹម យ៉ឹម មន្ត្រី នាយកដ្ឋានគ្រប់គ្រងកិច្ចការ TVET

២០-លោកស្រី អៀង សុចន្ទី លេខាធិការ នាយកដ្ឋានគ្រប់គ្រងកិច្ចការ TVET
២១-លោកស្រី តាន់ ស៊ីណា មន្ត្រី នាយកដ្ឋានគ្រប់គ្រងកិច្ចការ TVET
២២-លោក ហែម សារឿន មន្ត្រី វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ
២៣-លោកស្រី ពេជ ទិច្ឆិរ៉ា គ្រូ វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ
២៤-លោក ធឹង ពីត គ្រូ វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ
២៥-លោក ម៉ឹម សុផើ គ្រូ វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ
២៦-លោក ម៉ុង ទីរិយ៉ា មន្ត្រី វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ
២៧-លោក ប៉ែន សុគន្ធី លេខាធិការ វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ
២៨-លោក ឆន់ ស៊ីខឿន មន្ត្រី វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា
២៩-លោក អ៊ុក ផល្លី គ្រូ សាលាអប់រំបច្ចេកទេសភ្នំពេញ
៣០-លោក គាត ពុធណារិទ្ធ មន្ត្រី នាយកដ្ឋានសន្តិសុខសង្គម
៣១-លោកស្រី សេង ធារី មន្ត្រី នាយកដ្ឋានពេទ្យការងារ
៣២-កញ្ញា អ៊ុំ នាង មន្ត្រី នាយកដ្ឋានពេទ្យការងារ
៣៣-លោក ខៀវ សុធារ៉ា មន្ត្រី អធិការកិច្ចការងារ នាយកដ្ឋានអធិការកិច្ចការងារ
៣៤-កញ្ញា អាន សុលី មន្ត្រី អធិការកិច្ចការងារ នាយកដ្ឋានអធិការកិច្ចការងារ
៣៥-លោក ម៉ូ វ៉ាផាត់ មន្ត្រី អគ្គាធិការដ្ឋាន
៣៦-លោក អ៊ឹម សុផល អនុប្រធានមន្ទីរ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ស្ពឺ
៣៧-លោក ចេង ហ៊ាង អនុប្រធានមន្ទីរ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ចាម
៣៨-លោក ឃៀប លីនណា អនុប្រធានមន្ទីរ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តស្ទឹងត្រែង
៣៩-លោក ឌុច ចាន់តូ អនុប្រធានមន្ទីរ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តរតនគិរី
៤០-លោក ឈុប សាវ៉ាត់ អនុប្រធានមន្ទីរ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តព្រៃវែង
៤១-លោក នាក់ ណាង អនុប្រធានមន្ទីរ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុងប៉ៃលិន
៤២-លោក គី ឡុងឌី អនុប្រធានមន្ទីរ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុងប៉ៃលិន
៤៣-លោក ឈុប សាលុច្ស អនុប្រធានមន្ទីរ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុងប៉ៃលិន
៤៤-លោក ធឹង សុខជា អនុប្រធានមន្ទីរ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប
៤៥-លោកស្រី ម៉ុន ច្រិប អនុប្រធានមន្ទីរ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប
៤៦-លោក គង្គ សាវ៉ាត អនុប្រធានមន្ទីរ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុងកែប
៤៧-លោក នូ សុខុន អនុប្រធានមន្ទីរ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង
៤៨-លោក ហេ សុខសាយ អនុប្រធានមន្ទីរ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តក្រចេះ
៤៩-លោក ហុង សុគន្ធ អនុប្រធានមន្ទីរ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានីភ្នំពេញ
៥០-លោក ហុង ប្រុកប អនុប្រធានមន្ទីរ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តបន្ទាយមានជ័យ
៥១-លោកស្រី ធឹន ម៉ារីន អនុប្រធានមន្ទីរ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តបន្ទាយមានជ័យ
៥២-លោក ម៉ឿន វុទ្ធី ប្រធានការិយាល័យ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តបាត់ដំបង
៥៣-លោក ហាក់ សេងហួរ ប្រធានការិយាល័យការងារ មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ចាម
៥៤-លោក ស៊ឹម វេនៈ ប្រធានការិយាល័យ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុងព្រះសីហនុ
៥៥-លោក អ៊ូ សុខឿន ប្រធានការិយាល័យការងារ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តស្វាយរៀង
៥៦-លោក សៅ សុគន្ធ ប្រធានការិយាល័យ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តស្ទឹងត្រែង
៥៧-លោកស្រី ចាន់ សុផា ប្រធានការិយាល័យការងារ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង

| | | | |
|---|---|---|---|
| ៥៨-លោក | គង់ | គីមឌី | ប្រធានការិយាល័យ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល |
| ៥៩-លោកស្រី | ផៃ | ផល្លា | ប្រធានការិយាល័យ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តបាត់ដំបង |
| ៦០-លោក | ប៊ួយ | ប្រុស | នាយកសាលាបឹងនិមល មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពត |
| ៦១-លោកស្រី | ផង់ | ពុទ្ធី | នាយិកា PTC ខេត្ត មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប |
| ៦២-លោកស្រី | ដេត | ឡើម | នាយិកាសាលាការដ្ឋាន មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប |
| ៦៣-លោកស្រី | ដួង | ច័ាន់ដេត | នាយិកាមណ្ឌល PTC ខេត្ត មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តបាត់ដំបង |
| ៦៤-លោក | សុខ | សេត្ថ | នាយកមណ្ឌលព្រៃកូនខ្លា មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តបាត់ដំបង |
| ៦៥-លោក | អ៊ុក | ដាវ៉ាន់ឌី | នាយក VTC ខេត្ត មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តបាត់ដំបង |
| ៦៦-លោក | ឈាង | អៀមឡេង | អនុប្រធានការិយាល័យការងារ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ចាម |
| ៦៧-លោក | យឹម | សុផល | អនុប្រធានការិយាល័យគណនេយ្យ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ស្ពឺ |
| ៦៨-លោក | ឈឹង | វៀង | អនុប្រធានការិយាល័យការងារ មន្ទិរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុងព្រះសីហនុ |
| ៦៩-លោក | ជុំ | សាគុណា | នាយករងមជ្ឈមណ្ឌល មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តតាកែវ |
| ៧០-លោក | ម៉ែក | សាខន | មន្ត្រីរដ្ឋបាល មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ស្ពឺ |
| ៧១-លោក | ស៊ឿ | សារះខាន់ | មន្ត្រីការិយាល័យគណនេយ្យ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ចាម |
| ៧២-លោក | ហុង | នៅ | គ្រូ សាលាមធ្យមសិក្សាបច្ចេកទេសឧស្សាហកម្ម |
| ៧៣-លោក | ប៊ី | ស៊ីវត្ថា | លេខាធិការ វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស |
| ៧៤-លោក | ហ៊ីម | សារឿន | គ្រូ វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសមៈ |
| ៧៥-លោក | ឌិន | យ៉ាន | គ្រូ សាលាមធ្យមសិក្សាបច្ចេកទេសឧស្សាហកម្ម |
| ៧៦-លោក | ស៊ូ | សុវណ្ណ | លេខាធិការ នាយកដ្ឋានគ្រប់គ្រងកិច្ចការ TVET |
| ៧៧-លោក | មាស | អេង | មន្ត្រី សាលាមធ្យមសិក្សាបច្ចេកទេសឧស្សាហកម្ម |
| ៧៨-លោកស្រី | នេព | សុវណ្ណារី | លេខាធិការ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ៧៩-លោក | មាស | សាដាត | មន្ត្រី នាយកដ្ឋានពេទ្យការងារ |
| ៨០-លោក | យក់ | សេង | មន្ត្រី មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ធំ |
| ៨១-លោក | នួច | ទ្រី | ប្រធានការិយាល័យស្រុកមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពត |
| ៨២-លោកស្រី | អ៊ុន | សារ៉ែន | មន្ត្រី ការិយាល័យកណ្តាល |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:....៩៦៦ អនក្រ.បក

## អនុក្រឹត្យ

